ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

លេខ ៖ .......០១........ ព.ម.សរ

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០

## សារាចរ

## ស្តីពីការបោះពុម្ពផ្សាយ ដើម្បីធ្វើពាណិជ្ជកម្ម

ក្រសួងព័ត៌មាន បានពិនិត្យឃើញថា ការងារបោះពុម្ភផ្សាយនៅព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន កំពុងមានការរីកចំរើន និង វិវត្ត ទៅមុខឥតឈប់ឈរ ដែលបានចូលរួមចំណែកបំពេញសេចក្តីត្រូវការ ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ក្នុងការសិក្សាអប់រំ ស្រាវ ជ្រាវ ការកំសាន្ត និងធម្មជាតិ ទឹកដីជាទីគោរពស្រលាញ់របស់មាតុភូមិយើង ហើយលើសពីនេះទៀត បានផ្សាភ្ជាប់ប្រជាជនយើង ទៅនិង ការ អភិវឌ្ឍនានា ជាមួយប្រជាជាតិលើសកលលោកទៀតផង ។

ក្រសួងព័ត៌មាន សូមកោតសរសើរដល់ម្ចាស់គ្រឹះស្ថានបោះពុម្ពផ្សាយ ម្ចាស់រោងពុម្ព និងម្ចាស់អាជីវកម្មបោះពុម្ព ខ្នាតតូច ខ្នាត មធ្យម ទាំងអស់រាប់ទាំងការបោះពុម្ពដោយអូសស្បៃ និងហ្វូតូកូពី ជាដើម ។ល។ ដែលបានគោរពប្រតិបត្តិបានយ៉ាងល្អនូវច្បាប់ របស់ ប្រទេស និងសេចក្តីណែនាំ បទបញ្ជាទាំងឡាយរបស់ក្រសួងព័ត៌មាន ក្នុងការប្រកបអាជីវកម្មកន្លងមក ។ ទន្ទឹមនឹងការខិតខំ ប្រឹងប្រែង អនុវត្តយ៉ាងខ្ជាប់ខ្ជួននេះ ក៏នៅមានម្ចាស់អាជីវកម្មបោះពុម្ពខ្លះ នៅពុំទាន់យកចិត្តទុកដាក់អនុវត្តច្បាប់ ក៏ដូចជាបទបញ្ជារបស់ ក្រសួង ព័ត៌មាននៅឡើយ ដោយលួចធ្វើការបោះពុម្ពឡើងវិញ លួចថតចម្លងសៀវភៅគ្រប់ប្រភេទ ឯកសារផ្សេងៗ ស្តីពីអក្សរសាស្ត្រ ប្រវិត្តសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំជាដើម ដែលជាស្នាដៃរបស់អ្នកនិពន្ធទៅដាក់លក់ធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ជាពិសេស ផលប្រយោជន៍ អ្នកនិពន្ធខ្មែរយើង ។ ម្យ៉ាងទៀត ការលួចបោះពុម្ព សៀវភៅ និងឯកសារផ្សេងៗ ជាស្នាដៃបង្កើត តាមគំនិត ប្រាជ្ញាផ្ទាល់របស់អ្នកនិពន្ធ ដែលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ផ្តាច់មុខលើស្នាដៃនោះ គឺជាអំពើផ្ទុយនឹងច្បាប់ស្តីពីនេះអ្នក និពន្ធ និងសិទ្ធិ ប្រហាក់ប្រហែល ហើយនឹង ត្រូវមានទោសតាមច្បាប់ប្បញ្ញត្តិ ។ ដើម្បីរួមចំណែកលើកតំកើងការគោរពច្បាប់ កិត្តិយសជាតិ លើកទឹក ចិត្តដល់អ្នកនិពន្ធខ្មែរយើង និងការពារស្នាដៃអ្នកនិពន្ធ ដែលកំពុងចរាចរច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងព័ត៌មាន ចេញសារាចរ ណែនាំ ដល់គ្រប់ កន្លែង អាជីវកម្មបោះពុម្ពទាំងអស់ថា: រាល់ផលិតផលបោះពុម្ពត្រូវដាក់ឈ្មោះ និងអាស័យដ្ឋានរោងពុម្ព ថ្ងៃ ខែ ឆ្នាំបោះពុម្ព បោះបុម្ពលើកទីមួយ ឬលើកទីពីរ ឈ្មោះអ្នកនិពន្ធ ។ ហាមឃាត់ដាច់ខាតការលួចបោះពុម្ពចម្លងស្នាដៃនិពន្ធ ក្នុងករណីល្មើសត្រូវដកហូតអាជ្ញាប័ណ្ណ បញ្ឈប់ អាជីវកម្មបោះពុម្ពជាស្ថាពរ និងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

សារាចរនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

ចម្លងជូន :
- -ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យលោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
- -ក្រសួងមហាផ្ទៃ
- -សាលារាជធានី-ខេត្ត

  "ដើម្បីជូនជ្រាប"
- -រាជកិច្ច

Create PDF files without this message by purchasing novaPDF printer (http://www.novapdf.com)